# បន្ទប់ស្ថានការណ៍ ថ្ងៃបោះឆ្នោត ឆ្នាំ២០១៣
## Situation Room on Cambodia Election Day 2013

## សេចក្តីថ្លែងការណ៍
## ស្តីពី
## ការថ្កោលទោសចំពោះការបាញ់ប្រហារប្រជាពលរដ្ឋ

ភ្នំពេញ, ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៣ វេលាម៉ោង ១១យប់

បន្ទប់ស្ថានការណ៍នៃសមាគម និងអង្គការសង្គមស៊ីវិលនៅកម្ពុជា សូមថ្កោលទោសចំពោះការបាញ់ប្រហារប្រជាពលរដ្ឋដែលបណ្តាលឲ្យស្លាប់ និងរងរបួសមួយចំនួន។ ករណីហិង្សានេះបានកើតឡើងនៅស្ពានអាកាសក្បាលថ្នល់នៅរាត្រីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៣។

បន្ទប់ស្ថានការណ៍នៃសមាគម និងអង្គការសង្គមស៊ីវិលនៅកម្ពុជាស្នើឲ្យរាជរដ្ឋាភិបាលចាត់វិធានការបញ្ឈប់ការបាញ់ប្រហារពីសំណាក់ក្រុមកម្លាំងប្រដាប់អាវុធលើប្រជាពលរដ្ឋស្លូតត្រង់ជាបន្ទាន់។ ហើយរាជរដ្ឋាភិបាលត្រូវចាត់វិធានការច្បាប់ចំពោះអ្នកបញ្ជា និងជនដៃដល់ ដែលបានប្រព្រឹត្តិអំពើបាញ់ប្រហារប្រជាពលរដ្ឋ។ យើងក៏សំណូមពរផងដែរ ឲ្យមានការដោះលែងប្រជាពលរដ្ឋដែលត្រូវបានចាប់ខ្លួនទាក់ទិននឹងព្រឹត្តិការណ៍នេះ។

បន្ទប់ស្ថានការណ៍នៃសមាគម និងអង្គការសង្គមស៊ីវិលនៅកម្ពុជា មានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះស្ថានភាពបាតុកម្មអហិង្សារបស់គណបក្សសង្គ្រោះជាតិដែលនឹងបន្តធ្វើនៅថ្ងៃទី១៦ និង១៧ ខែកញ្ញា ឆ្នាំ ២០១៣។ ដូចនេះយើង ស្នើសុំឲ្យសហគមន៍អន្តរជាតិ និងអ្នកសង្កេតការណ៍ជាតិ និង អន្តរជាតិ ចូលរួមឃ្លាំមើលព្រឹត្តិការណ៍ខាងលើនេះ និងអន្តរាគមឲ្យបានទាន់ពេលវេលាដើម្បីបញ្ឈប់ករណីរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរដូចករណីខាងលើ។

**ព័ត៌មានបន្ថែមសូមទាក់ទង៖**

| | | |
|---|---|---|
| ១. លោក ធន សារាយ | ប្រធានសមាគមអាដហុក | 016 880 509 |
| ២. លោក គល់ បញ្ញា | នាយកប្រតិបត្តិ Comfrel | 012 942 017 |
| ៣. លោក យ៉េង វីរៈ | នាយកប្រតិបត្តិ CLEC | 066 777 000 |
| ៤. លោក ប៉ា ងួនទៀង | នាយកប្រតិបត្តិ CCIM | 060 409 999 |